# សុន្ទរកថា

## លោកជំទាវបណ្ឌិត. អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## ក្នុងឱកាស

## ផ្សព្វផ្សាយនូវរបាយការណ៍នៃការសិក្សាស្រាវជ្រាវ ស្តីពី

## "ដំណើរឆ្ពោះទៅមុខដើម្បីសមភាពយេនឌ័រ ស្ត្រី និងប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា"

## និងអបអរសាទរទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០១៨

ថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ថ្ងៃទី ០៣ ខែឧសភាឆ្នាំ ២០១៨ រាជធានីភ្នំពេញ

- លោកជំទាវ **Maria Sargren** ឯកអគ្គរាជទូតប្រទេសស៊ុយអែត ប្រចាំព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម **ថាច់ ផែន** រដ្ឋលេខាធិការ ក្រសួងព័ត៌មាន

-លោកស្រី Anne Lemaistre ប្រធានអង្គការយូណេស្កូប្រចាំកម្ពុជា

-លោកជំទាវ ឯកឧត្តម លោកស្រី លោក ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ ដែលមានវត្តមាននៅទីនេះ:

***អរុណសួស្តី !***

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ អង្គការ UNESCO ដែលបានផ្តល់កិត្តិយសឱ្យខ្ញុំ ចូលរួមបើកកម្មវិធី ការផ្សព្វផ្សាយជាផ្លូវការនូវរបាយការណ៍ការសិក្សាស្រាវជ្រាវ ស្តីពី "ដំណើរឆ្ពោះទៅមុខដើម្បីសមភាពយេនឌ័រ ស្ត្រី និងប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា" ជាភាសាអង់គ្លេស "Towards Gender Equality: Women and Media in Cambodia" ដែលធ្វើការសិក្សាស្រាវជ្រាវដោយវិទ្យាស្ថាន Fojo Media និងមានការគាំទ្រថវិកាពីប្រទេសស៊ុយអែត និងអង្គការ UNESCO និងចូលរួមអបអរសាទរទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០១៨។

ឆ្លៀតក្នុងឱកាសនៃការរំលឹកដល់ទិវាសេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០១៨នេះ ខ្ញុំសូមសម្តែងនូវគារវកិច្ច ជាពិសេសដល់ស្ត្រីជាអ្នកសារព័ត៌មាន ដែលមានវត្តមាននៅទីនេះ។ ស្ត្រីជាអ្នកសារព័ត៌មាន និងអ្នកនិពន្ធ គឺជាអ្នកចូលរួមចំណែកក្នុងការកំណត់ដំណើរនៃប្រវត្តិសាស្ត្រ និងផ្តល់នូវការយល់ដឹងអំពីជីវិត និងបទពិសោធន៍របស់មនុស្សទូទាំងពិភពលោក។ យើងទាំងអស់គ្នា មានការយល់ដឹងអំពីសង្គម និងជីវិតមនុស្ស ក៏ដូចជាបទពិសោធន៍ជាច្រើន ក៏ដោយសារកាលពីដើមឡើយយើងមានអ្នកសារព័ត៌មានចំណានៗជាច្រើនដែលខិតខំប្រឹងប្រែងស្វែងរកព័ត៌មានពិតដើម្បីចងក្រងជាឯកសារ និងត្រួសត្រាយផ្លូវអោយអ្នកសារព័ត៌មានជំនាន់ក្រោយ ។ ក្នុងនោះមាន លោកស្រី Flora Tristan ជាអ្នកយកព័ត៌មាន បារាំងប៉េរូ(French-Peruvian)ដែលជាអ្នកត្រួសត្រាយ និងចងក្រងឯកសារអំពីភាពក្រីក្រ

ដោយធ្វើការដកស្រង់ចេញពីសង្គមនៅទីបអ៊ីរ៉ុបក្នុងកំឡុង នៃស.វទី១៩ ព្រមទាំងបានស្វែងរកការគាំទ្រមតិក្នុងការលុបចោលទាសភាពលើមនុស្ស។

ឧទាហរណ៍មួយទៀតគឺ លោកស្រី Ida Bell Wells ដែលជាអ្នកសារព័ត៌មាន ដ៏ល្បីល្បាញជនជាតិអាហ្វ្រិក-អាមេរិក (African-American)។ គាត់ជាអ្នកសារព័ត៌មានបែបស៊ើបអង្កេតនិងជាសកម្មជនសិទ្ធិមនុស្សដែលកើតក្នុងសម័យទាសភាព នៃស.វទី១៩ ដែលគាត់បានសរសេរយ៉ាងក្បោះក្បាយ អំពីអំពើហិង្សាដែលជនជាតិស្បែកខ្មៅបានទទួលរងនៅក្នុងសហរដ្ឋអាមេរិក។

អ្នកសារព័ត៌មានស្ត្រីដ៏អស្ចារ្យម្នាក់ទៀត គឺលោកស្រី Nellie Bly (ឆ្នាំ១៨៦៤ ដល់ឆ្នាំ ១៩២២) ដែលមានភាពល្បីល្បាញ អំពីដំណើរផ្សងព្រេងរបស់លោកស្រី នៅជុំវិញពិភពលោកក្នុងរយៈពេល ៧២ ថ្ងៃ បំបែកកំណត់ត្រារបស់ លោក Jules Verne's ដែលធ្វើដំណើរជុំវិញពិភពលោក ក្នុងពេល ៨០ ថ្ងៃ។ ក្រៅពីសមិទ្ធផលនេះលោកស្រី Nellie Bly ក៏បានក្លាយជាអ្នកច្នៃប្រឌិតថ្មីនិងជាស្ថាបនិកនៃបណ្តាញសារព័ត៌មានថ្មីមួយដែលគេហៅថា អ្នកសារព័ត៌មានស៊ើបអង្កេតស៊ីជម្រៅ " Immersive journalism " ។

បន្ថែមពីលើនេះ ខ្ញុំក៏សូមលើក និងកោតសរសើរដល់អ្នកសារព័ត៌មានឆ្នើមជាស្ត្រីរូបមាន លោកស្រី Nawual El Saadawi ដែលគេចាត់ទុកគាត់ជាអ្នកនិពន្ធឆ្នើមប្រៀបធៀបដូច លោកស្រី Simone de Beauvoir នៃពិភពអារ៉ាប់ គឺជាអ្នកនិពន្ធល្បីល្បាញ មានកំណើតនៅប្រទេសអេហ្ស៊ីបក្នុងឆ្នាំ ១៩៣១ និងនៅរស់រានមានជីវិតដល់សព្វថ្ងៃ។ កន្លងមកលោកស្រីបាន ឆ្លងកាត់ភាពឈឺចាប់ពីការកាត់សរីរាង្គបន្តពូជផ្នែកខាងក្រៅ (Genital Mutilation) ក្នុងវ័យកុមារភាព។ លោកស្រីបានក្លាយជាសកម្មជនសិទ្ធិស្ត្រីនៅក្នុងពិភពអ៊ីស្លាម ធ្វើអោយពិភពលោកទទួលស្គាល់និងបានផ្តល់រង្វាន់អន្តរជាតិជាច្រើនជូនលោកស្រី។

អ្នកនិពន្ធដ៏គួរឱ្យចាប់អារម្មណ៍វ័យក្មេងម្នាក់ទៀតគឺ លោកស្រី Katrine Marçal ជនជាតិស៊ុយអែតដែលសរសេរសៀវភៅ មានចំណងជើងថា Who Cooked Adam Smith's Dinner? នៅឆ្នាំ២០១៦។ សៀវភៅនេះផ្តល់ទស្សនលើការអភិវឌ្ឍសេដ្ឋកិច្ចបែបស្ត្រីនិយមដ៏ឈ្លាសវៃ និងបានបំផុសគំនិតរិះគន់ទៅលើទស្សនសេដ្ឋកិច្ចដឹកនាំដោយបុរស "Economic Man" ដែលមានចរិកផ្អែកលើហេតុផល ក៏ប៉ុន្តែអត្មានិយម ស្វែងរកប្រាក់ចំណេញហួសហេតុ មានលក្ខណៈផ្តាច់ខ្លួន ធ្វើឱ្យការអភិវឌ្ឍមិនមានលក្ខណៈបរិយាប័ន្ន និងផ្តាច់ខ្លួនពីតម្រូវការពិតរបស់មនុស្ស។ ដូចដែលលោកស្រីបានលើកឡើងថា នៅពេលដែលមនុស្សគ្រប់រូប កំពុងឋិតក្នុងភាពងាយរងគ្រោះ និងត្រូវការពឹងពាក់គ្នាទៅវិញទៅមក យើងទាំងអស់គ្នានឹងទទួលបានវឌ្ឍនភាពពីកិច្ចសហប្រតិបត្តិការ ជាជាងការប្រកួតប្រជែង។

អ្នកសារព័ត៌មានស្ត្រីដែលមានឈ្មោះល្បីល្បាញក្នុងសហសម័យនៅលើពិភពលោក ដែលគួរលើកផងដែរមាន លោកស្រី Lijia Zhang ជនជាតិចិន និង លោកស្រី Christiane Amanpour កូនកាត់ជនជាតិអង់គ្លេសអ៊ីរ៉ង់ជាដើម។ មានស្ត្រីអ្នកសារព័ត៌មានជាច្រើនទៀតដែលខ្ញុំមិនអាចរៀបរាប់ទាំងអស់ក្នុងពេលនេះ។

អ្វីដែលជាការកត់សម្គាល់របស់ខ្ញុំ អ្នកសារព័ត៌មាន និងអ្នកនិពន្ធស្ត្រីទាំងអស់ដែលខ្ញុំបានលើកឡើង ក៏ដូចជាអ្នកសារព័ត៌មានផ្សេងៗទៀត មានចំណុចរួមដូចគ្នា ដោយពួកគេបានលើកនូវរឿងពិតរបស់មនុស្សគ្រប់ស្រទាប់វណ្ណៈ ហើយជាពិសេសរឿងរ៉ាវរបស់ស្ត្រី បុរស និងកុមារដែលរស់នៅក្នុងសង្គមមួយដែលសង្គមទូទៅមិនបានចាប់អារម្មណ៍ ឬនឹកគិតដល់។ ស្ត្រីអ្នកសារព័ត៌មាន អធិប្បាយអំពីសាច់រឿង តាមរយៈទស្សនៈដាច់ដោយឡែករបស់ខ្លួន ដោយប្រើប្រាស់អារម្មណ៍ ភាសា និងការយល់ដឹងរបស់ពួកគេនៅលើអ្វីដែលមានសារៈសំខាន់សម្រាប់ជីវិតរស់នៅ។ ស្ត្រីជាអ្នកសារព័ត៌មាន និងជាអ្នកនិពន្ធ បានធ្វើអោយវិស័យសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ មានភាពប្រសើរឡើងលើផ្នែកវិជ្ជាជីវៈ ផ្នែកមនុស្សធម៌ និងមានអត្ថន័យសម្រាប់យើងទាំងអស់គ្នា ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាមិនយូរប៉ុន្មាន អ្នកសារព័ត៌មានស្ត្រីខ្មែរ នឹងអាចអភិវឌ្ឍខ្លួនឈានទៅរកភាពល្បីល្បាញនៅលើប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិផងដែរ។

**លោកជំទាវ ឯកឧត្តម លោកស្រី លោក ជាទីមេត្រី!**

យើងត្រូវបង្កើនចំនួនស្ត្រីក្នុងក្រុមប្រឹក្សានាយកនៃស្ថាប័នសារព័ត៌មាន និងបង្កើនចំនួនស្ត្រីជានិពន្ធនាយក និងអ្នកយកព័ត៌មាន។ មិនតែប៉ុណ្ណោះយើងត្រូវបង្កើនការយល់ដឹងផ្នែកយេនឌ័ររបស់ពួកគេ ដើម្បីបង្កើនគុណភាពនៃសេចក្តីរាយការណ៍ព័ត៌មាន ជាពិសេសព័ត៌ដែលមានផលប៉ះពាល់ ឬទាក់ទងនឹងស្ត្រី។ ដូចគ្នានេះដែរ ស្ថាប័នសារព័ត៌មាន គួរផ្តល់ការចាប់អារម្មណ៍ និងបង្កលក្ខណៈងាយស្រួលឱ្យស្ត្រី ជាពិសេសអ្នកជំនាញស្ត្រី ចូលរួមចែករំលែកនូវទស្សនៈ ក្នុងអត្ថបទសារព័ត៌មាន។ យើងដឹងថា មានស្ត្រីកម្ពុជាជាច្រើនដែលបានបង្កើតស្នាដៃ និងសម្រេចបាននូវសមិទ្ធផលដ៏វិជ្ជមាននៅក្នុងសហគមន៍ ក៏ដូចជាសង្គមទាំងមូល ប៉ុន្តែស្នាដៃទាំងនេះ មិនត្រូវបានរំលេចនៅក្នុងចំណងជើងរបស់សារព័ត៌មានឡើយ ដោយសារតែវិសមភាពយេនឌ័រក្នុងវិស័យសារព័ត៌មាន។

នៅក្នុងការសិក្សាដែលយើងកំពុងផ្សព្វផ្សាយនៅថ្ងៃនេះ បានរកឃើញថា "អ្នកសារព័ត៌មានមួយចំនួននៅខ្វះជំនាញ និងចំណេះដឹងក្នុងការធ្វើសេចក្តីរាយការណ៍ប្រកបដោយគុណភាព និងគោរពតាមក្រមសីលធម៌ ជាពិសេសការធ្វើសេចក្តីរាយការណ៍ដែលប៉ះពាល់នឹងស្ត្រី ក៏ដូចជាខ្វះខាតនូវចំណេះដឹងក្នុងការប្រើប្រាស់បច្ចេកស័ព្ទឱ្យបានត្រឹមត្រូវ" ផងដែរ។

ក្នុងន័យនេះ ខ្ញុំមានសេចក្តីរីករាយ សូមជូនដំណឹងថាក្រសួងកិច្ចការនារីកំពុងដំណើរការរៀបចំឯកសារស្តីពីការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា២០១៨-២០២៣ ដែលជារបាយការណ៍ជាតិផ្តល់នូវការវិភាគអំពីយេនឌ័រនៅក្នុងគ្រប់វិស័យ។ របាយការណ៍ថ្នាក់ជាតិនេះនឹងផ្តល់បច្ចុប្បន្នភាពទាក់ទងនឹងព័ត៌មាន និងតួលេខអំពីស្ថានភាពស្ត្រីនៅកម្ពុជា ហើយនឹងរួមបញ្ចូលផងដែរនូវសៀវភៅ "សទ្ទានុក្រមយេនឌ័រ" ដែលមានដាក់បញ្ចូលនូវពាក្យថ្មីៗអំពីសមភាពយេនឌ័រ និងការកែសម្រួលពាក្យខ្លះៗ ដែល

មានប្រើប្រាស់នៅក្នុងកូនសៀវភៅដែលយើងបានផលិតកាលពីជាង ១០ឆ្នាំមុន។ ដូច្នេះ ការវាយតម្លៃយេនឌ័រនៅកម្ពុជាដែលនឹងប្រព្រឹត្តទៅនៅពេលខាងមុខនេះ នឹងក្លាយជាឧបករណ៍ដែលផ្អែកលើភស្តុតាង ដែលអាចឲ្យអ្នកសារព័ត៌មាន និងនិស្សិត យកទៅប្រើប្រាស់សម្រាប់សំណេរអំពីស្ថានភាពពិតនៃសមភាពយេនឌ័រ និងស្ត្រី។ នៅក្រោមក្របខ័ណ្ឌនៃកម្មវិធី"ដំណើរឆ្ពោះទៅមុខដើម្បីសមភាពយេនឌ័រ" ដោយមានការគាំទ្រពីប្រទេសស៊ុយអែដ និងអង្គការUNDP ក្រសួងកិច្ចការនារី កំពុងធ្វើការជាមួយក្រសួងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងគោលដៅលើកកំពស់ការកែប្រែឥរិយាបថរបស់សង្គមក្នុងគាំទ្រសមភាពយេនឌ័រ។ ជាការពិតណាស់ យើងបន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួងព័ត៌មាន និងក្លឹបអ្នកកាសែតកម្ពុជា ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "ក្រមវិជ្ជាជីវៈអ្នកសារព័ត៌មានស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ" ដែលយើងប្រកាសផ្សាយរួមគ្នាកាលពីខែមិថុនា ឆ្នាំ ២០១៧។

ខ្ញុំក៏សូមឆ្លៀតឱកាសនេះ ដើម្បីកែតម្រូវនូវព័ត៌មាននៅលើទំព័រលេខ ៣២ នៃរបាយការណ៍នៃការសិក្សាស្រាវជ្រាវដែលយើងកំពុងផ្សព្វផ្សាយនៅថ្ងៃនេះ។ នៅក្នុងរបាយការណ៍នេះបានធ្វើការរិះគន់ថា ក្រសួងកិច្ចការនារី "មានវិធានការតិចតួច" ចំពោះសេចក្តីរាយការណ៍ដែលទាក់ទងនឹងស្ត្រី។ ព័ត៌មានដែលបានបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍នេះមិនពិតនោះទេ ព្រោះក្រសួងកិច្ចការនារីបានយកចិត្តទុកដាក់ខ្ពស់ចំពោះបញ្ហានេះ។ ជាឧទាហរណ៍ ក្រសួងកិច្ចការនារី បានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈមួយថ្កោលទោសចំពោះអ្នកផ្សាយទូរទស្សន៍ដែលនិយាយកំប្លែងសើចចំអកអំពីការចាប់រំលោភ និងការសំលាប់ស្ត្រីកម្ពុជាម្នាក់នៅខែសីហាឆ្នាំ ២០១៧ ហើយសេចក្តីថ្លែងការនេះបានចុះផ្សាយនៅក្នុងសារព័ត៌មានផងដែរ។ ខ្ញុំ សូមបញ្ជាក់ផងដែរថា ក្រសួងកិច្ចការនារីមិនមានអំណាចឬសិទ្ធិអំណាចក្នុងការកាត់ទោស អ្នកសារព័ត៌មាន ដែលរំលោភលើក្រមវិជ្ជាជីវៈរបស់ប្រព័ន្ធផ្សព្វផ្សាយ ប៉ុន្តែក្រសួងមានតួនាទី បណ្តុះបណ្តាលនិងធ្វើឱ្យអ្នកសារព័ត៌មាន និងអ្នកនិពន្ធអោយយល់ដឹង និងទទួលខុសត្រូវនូវលើសេចក្តីរាយការណ៍របស់គាត់ដែលប្រាស់ចាកពីក្រមសីលធម៌ក្នុងការរាយការណ៍ព័ត៌មានស្តីពីអំពើហិង្សាលើស្ត្រី។

ជាទីបញ្ចប់ ខ្ញុំសូមអរគុណជាថ្មីម្តងទៀតជូនដល់អ្នករៀបចំកម្មវិធី ដែលបានផ្តល់កិត្តិយសឱ្យខ្ញុំចូលរួម និងសូមអនុញ្ញាតដកស្រង់សម្តីរបស់អ្នកសារព័ត៌មាន ឈ្មោះ Gloria Steinem ដែលនិយាយថា "មិនត្រូវគិតថា តើស្ត្រីធ្វើបែបណាឲ្យចុះសម្រុងនឹងពិភពលោកទេ ប៉ុន្តែត្រូវគិតថា តើពិភពលោកត្រូវធ្វើបែបណាទៅតាមការចង់បានរបស់ស្ត្រី"។សូមអរគុណ!